សុន្ទរកថា របស់

**លោកស្រី Francesca Erdelmann**

**នាយកប្រចាំប្រទេសនៃកម្មវិធីស្បៀងអាហារពិភពលោក**

តំណាងឲ្យ ក្រុមការងារទទួលបន្ទុកសន្តិសុខស្បៀង និងជីវភាពរស់នៅ

ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

ក្រសួងមហាផ្ទៃ

---

*សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមេត្រី!*

អរុណសួស្តី

សូមថ្លែងអំណរគុណចំពោះ លោកជំទាវ ជូ ប៊ុនអេង ដែលបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃសន្តិសុខស្បៀង និងជីវភាពរស់នៅ របស់ពលករចំណាកស្រុក ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ ក្នុងអំឡុងពេលពិគ្រោះយោបល់នាពេលថ្មីៗនេះ។ គ្រួសារដែលមានសមាជិកគ្រួសារធ្វើចំណាកស្រុកទៅក្រៅប្រទេស ឬក្នុងប្រទេសកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រាក់បញ្ញើ ដើម្បីទូទាត់ការចំណាយប្រចាំថ្ងៃ។ នៅឆ្នាំ ២០១៦ ការស្ទង់មតិមួយរបស់អង្គការសហប្រជាជាតិបានរកឃើញថា ប្រាក់ចំណូលទៀងទាត់ក្នុងប្រទេសប្រចាំឆ្នាំ របស់គ្រួសារពលករ ត្រូវបានបែងចែក ៦១% ទៅលើចំណាយប្រចាំឆ្នាំ ហើយភាគរយដែលនៅសល់ ៣៩% ទៀត សម្រាប់ផ្ញើរទៅផ្ទះ និងបង់ប្រាក់កម្ចី។

ការបាត់បង់ប្រាក់ចំណូលនេះ អាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសន្តិសុខស្បៀងរបស់គ្រួសារ។ ការបាត់បងប្រាក់ចំណូលនេះ អាចនឹងមានរយៈពេលយូរ ដោយសារតែផលប៉ះពាល់យ៉ាងខ្លាំងនៃជំងឺកូវីដ១៩ ធ្វើឱ្យមានឧបសគ្គយ៉ាងខ្លាំងទៅលើការចំណាយគ្រួសារ។ អាស្រ័យដូច្នេះ ជាការចាំបាច់ណាស់ក្នុងការគិតគូរពីតម្រូវការស្បៀងរយៈពេលខ្លី សម្រាប់ពលករចំណាកស្រុកដែលទើបវិលត្រលប់មកវិញ និងក្រុមគ្រួសាររបស់ពួកគេ ទន្ទឹមគ្នានឹងការស្វែងរកដំណោះស្រាយរយៈពេលមធ្យម និងវែង ដែលធានាដល់អំណាចក្នុងការទិញ និងឱកាសសម្រាប់ជម្រើសក្នុងការចិញ្ចឹមជីវិត ។ សមត្ថភាពរបស់ពួកគេក្នុងការទទួលបានអាហារដែលមានតំលៃសមរម្យ មានជីវជាតិ នៅលើទីផ្សារក្នុងសហគមន៍ នឹងមានសារៈសំខាន់សម្រាប់សុខមាលភាពអាហារូបត្ថម្ភយូរអង្វែង ជាពិសេសសម្រាប់កុមារតូចៗ មនុស្សវ័យជំទង់និ ងស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសាររបស់ពួកគេ។

នៅពេលពិនិត្យមើលយុទ្ធសាស្ត្រសមស្រប កម្មវិធីស្បៀងអាហារពិភពលោក អង្គការស្បៀងអាហារ និងកសិកម្ម និងទីភ្នាក់ងារអង្គការសហប្រជាជាតិដទៃទៀត ទទួលស្គាល់ថា វាជាការចាំបាច់ដែលយើងត្រូវយល់ដឹងពីតម្រូវការរបស់គ្រួសារ ពលករចំណាកស្រុកដែលទើបវិលត្រឡប់ និងគ្រួសារជិតខាង នៅក្នុងសហគមន៍របស់ពួកគេ។ ជាការពិតវាមានសារៈសំខាន់ផងដែរ ដើម្បីដឹងឱ្យកាន់តែច្បាស់អំពីទីកន្លែងនៅក្នុងខេត្ត ដែលពលករចំណាកស្រុកវិលត្រឡប់មករស់នៅ។ ខណៈពេលដែលការស្វែងរកលទ្ធភាពដើម្បីឆ្លើយតបនឹងតម្រូវការជាក់លាក់របស់ពលករចំណាកស្រុក ផលប៉ះពាល់កាន់តែខ្លាំងពីជំងឺកូវីដ១៩ ទាមទារ ឱ្យយើងដាក់ចេញយន្តការឆ្លើយតបឱ្យបានទូលំទូលាយ ក្នុងការគាំទ្រដល់ប្រជាពលរដ្ឋងាយរងគ្រោះបំផុត ដែលអាចរួមបញ្ចូលទាំងតម្រូវការរបស់គ្រួសារពលករចំណាកស្រុក។ កម្មវិធីចាំបាច់ត្រូវមានភាពស្មើភាព និងសមភាព សំរាប់ពលរដ្ឋទាំងអស់គ្នា ហើយជៀសវាងការគាំទ្រដល់មនុស្សមួយចំនួនតូច។

គ្មានការឆ្លើយតបណាមួយ អាចត្រូវបានរៀបចំឡើងដោយគ្មានទិន្នន័យគ្រប់គ្រាន់នោះទេ។ ដូច្នេះ <u>អាទិភាពទីមួយ</u> គឺត្រូវប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងទីកន្លែងស្នាក់នៅរបស់ពលករចំណាកស្រុក ដោយមានការគាំទ្រពីថ្នាក់ដឹកនាំខេត្ត និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ធ្វើការវិភាគទៅលើ ប្រជាសាស្ត្រ ជីវភាពរស់នៅ និងចរិតលក្ខណៈភាពងាយរងគ្រោះ នៃគ្រួសាររបស់ពួកគេ ដោយប្រើប្រាស់ទិន្នន័យដែលមានស្រាប់ពីវិទ្យាស្ថានជាតិស្ថិតិ និងប្រមូលព័ត៌មានថ្មីៗ។ និងស្វែងយល់ពីផលប៉ះពាល់នៃជំងឺកូវីដទី១៩ លើប្រព័ន្ធស្បៀងអាហារ និងជីវភាពរស់នៅតាមជនបទឲ្យមានលក្ខណៈទូលំទូលាយ ដោយមានការសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។

<u>ទីពីរ</u> យន្តការគាំទ្រផ្តោតលើគោលដៅជាក់លាក់ អាចត្រូវបានរៀបចំឡើង ក្នុងទម្រង់ផ្តល់ជូនកញ្ចប់រស់នៅមូលដ្ឋាន ក៏ដូចជាការដាក់បញ្ចូលគ្រួសារពលករចំណាកស្រុក ទៅក្នុងកម្មវិធីគាំទ្រដែលមានស្រាប់នៅក្នុងសហគមន៍របស់ពួកគេ។ យើងអាចជួយក្នុងការរៀបចំការបម្រុងទុកស្បៀងថ្នាក់ជាតិ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា មានបំណងធ្វើបែបនេះ ទន្ទឹមនឹងនេះ យើងក៏ធ្វើការជាមួយវេទិកាសង្គមស៊ីវិល ដើម្បីបង្កើតសមត្ថភាពរួម នៃអង្គការមិនមែនរដ្ឋាភិបាលរាប់រយ ដែលធ្វើការជាមួយសហគមន៍មូលដ្ឋាន ដែលអាចចូលរួមយ៉ាងសកម្មជាមួយគ្រួសារពលករចំណាកស្រុក សម្រាប់ទាំងការគាំទ្ររយៈពេលខ្លី និងវែង។

<u>ទីបី</u> សុខមាលភាព នៃពលករចំណាកស្រុក និងតម្រូវការគ្រួសាររបស់ពួកគេ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញ ទៅលើវិធានការណ៍នានា ដើម្បីផ្តល់ស្ថេរភាពសេដ្ឋកិច្ច និងសង្គម ដល់ប្រទេសទាំងមូល តាមរយៈប្រព័ន្ធស្បៀងអាហារ វិធានការខ្សែសង្វាក់ផលិតកម្ម និងកត្តាជំរុញទីផ្សារ។ វិធានការណ៍ជំនួយសង្គមដែលការពារគ្រួសារ ពីផលប៉ះពាល់អវិជ្ជមាន និងជំរុញការវិនិយោគរបស់ពួកគេនៅក្នុងឱកាសជីវភាពថ្មី។

ស្ថេរភាពសេដ្ឋកិច្ច និងសង្គម ក៏អាចកើតឡើង តាមរយៈគំនិតផ្តួចផ្តើមថ្នាក់ឃុំ ដែលត្រូវនឹងឆ្លើយតទៅនឹងតម្រូវការ មធ្យោបាយ និងឱកាសជាក់លាក់របស់សហគមន៍។ ជាការពិតណាស់ ជាទីបញ្ចប់ពលករចំណាកស្រុកនឹងទទួលបានអត្ថប្រយោជន៍ពីការបណ្តុះបណ្តាលជំនាញថ្មី ដែលផ្តល់ឱ្យពួកគេនូវទីផ្សារការងារកាន់តែច្រើន។

ឯកឧត្តម លោកជំទាវ! អង្គការសហប្រជាជាតិ មានកិត្តិយសដោយទទួលបានការជឿទុកចិត្តពីសំណាក់ក្រសួងមហាផ្ទៃ ក្នុងការបំពេញការងារជាមួយអ្នកទាំងអស់គ្នា ដើម្បីគាំទ្រដល់ប្រជាពលរដ្ឋកម្ពុជាក្នុងកាលទេសៈដ៏លំបាកនេះ។ នេះសរបញ្ជាក់យ៉ាងច្បាស់អំពីកិច្ចខិតខំប្រឹងប្រែងជាក្រុម ដោយហេតុថាមានសកម្មភាពជាច្រើនដូចដែលខ្ញុំទើបតែបានលើកឡើង អនុលោមទៅតាមអាណត្តិការងាររបស់ឯកឧត្តម លោកជំទាវ ដែលមានវត្តមាននៅថ្ងៃនេះ។ យើងខ្ញុំ ទន្ទឹងរងចាំ ពិភាក្សា និងស្វែងយល់នូវផែនការ ឱកាស និងបញ្ហាប្រឈមរបស់អ្នក ដើម្បីរៀបចំខ្លួនយើងបំពេញភារកិច្ចដ៏ចាំបាច់នេះ ក្នុងភាពជាដៃគូរជាមួយឯកឧត្តម លោកជំទាវ។

សូមអរគុណ។